ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...០៤...សរណន

# សារាចរណែនាំ

ស្តីពី

## ការចាត់តាំងខួបអន្តរជាតិលើកទី ១១៧ ទិវាពលកម្មអន្តរជាតិ ០១ ឧសភា ឆ្នាំ ២០០៣

*****

ទិវាពលកម្មអន្តរជាតិ ១ឧសភា គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃចលនាកម្មករអន្តរជាតិ ដែលចាប់ផ្តើមឡើងនាឆ្នាំ ១៨៨៦ ក្នុងគោលបំណងធ្វើអោយប្រសើរឡើងនូវស្ថានភាពនៃលក្ខខណ្ឌការងារ និង ជីវភាពរស់នៅ របស់ប្រជាពលករ។ នៅកម្ពុជា ទិវាពលកម្មអន្តរជាតិ ០១ ឧសភា ត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំ តាំងពីក្រោយថ្ងៃ ០៧ មករា ១៩៧៩ មកហើយមកដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលក៏បានកំណត់យកថ្ងៃ ០១ ឧសភា ជាថ្ងៃបុណ្យ ការងាររបស់ពលករ កម្ពុជា និងជាថ្ងៃឈប់សំរាករបស់កម្មករ និយោជិត។ បណ្តាស្ថាប័នរដ្ឋ កម្មករ និយោជិតនៃរោងចក្រ សហគ្រាសជាច្រើនបាន រៀបចំទិវានេះ ក្រោមបរិយាកាសសប្បាយរីករាយ សាមគ្គីភាព។ ទន្ទឹមនឹងនេះក៏មានក្រុមជនមួយ ចំនួនឆ្លៀតយកទិវា នេះ បង្កការទាមទារផ្សេងៗ រហូតបង្កើតជាអំពើហិង្សា ។

ដើម្បី អោយការប្រារព្ធទិវាពលកម្មអន្តរជាតិ ០១ ឧសភា ខួបលើកទី ១១៧ ប្រព្រឹត្តទៅបានល្អ រាជរដ្ឋាភិបាល សូមធ្វើការណែនាំដូចខាងក្រោមនេះ :

១-ក្រសួងពត៌មាន ម៉ាស៊ីនឃោសនារបស់រដ្ឋត្រូវផ្សព្វផ្សាយ ឱ្យសង្គមជាតិទាំងមូល យល់ពីអត្ថន័យទិវាពលកម្មអន្តរជាតិ ០១ ឧសភា ថាជាសមិទ្ធផលរបស់មនុស្សជាតិ ដែលបានបង្កើតនូវ លក្ខខណ្ឌការងារជាស្តង់ដារ សំរាប់ការអនុវត្តសព្វថ្ងៃនេះ ជាអាទិ៍ ពាក្យស្លោក ៨ ម៉ោងធ្វើការ ៨ ម៉ោងសំរាក ៨ ម៉ោងរៀនសូត្រ ជាដើម។

ព្រះរាជាណាចក្រកម្ពុជា បាន និងកំពុងអនុវត្តលក្ខខណ្ឌការងារ ធានាសិទ្ធិផលប្រយោជន៍កម្មករនិយោជិតតាមច្បាប់ស្តីពីការងារ និងបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិខាងការងារចំនួន១២ ក្នុងនោះមានអនុសញ្ញាស្នូលចំនួន៦។ ឆ្នាំ ២០០២ កន្លងមកនេះកម្ពុជាបានបង្កើតច្បាប់ស្តីពីរបបសន្តិសុខសង្គម សំរាប់ជនទាំងឡាយដែលស្ថិត ក្រោមបទបញ្ញត្តិនៃច្បាប់ ស្តីពីការងារ ក្នុងគោលបំណងធ្វើអោយលក្ខខណ្ឌការងារ និងជីវភាពរបស់កម្មករ និយោជិតកាន់តែ

ប្រសើរឡើង។ ទន្ទឹមនឹងការពង្រឹងការអនុវត្តច្បាប់ដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា យើងបាន អនុវត្តគំរោងឃ្លាំមើលលក្ខខណ្ឌការងារឯករាជ្យដែលចាត់ចែងដោយអង្គការអន្តរជាតិ ខាងការងារ (ILO)។ សិទ្ធិសហជីព សិទ្ធិកូដកម្ម ឡុកអៅ ត្រូវបានអនុវត្តយ៉ាងពេញលេញ។ គណៈកម្មការប្រឹក្សាការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ជាយន្តការត្រីភាគី ត្រូវបានរៀបចំអនុវត្តតួនាទីភារកិច្ចយ៉ាងសកម្ម ។ វិស័យការងារកម្ពុជា កំពុងជាកំលាំងជំរុញថ្មីមួយនៃការ ពង្រីកទីផ្សារនាំចេញផលិតផលទៅអាមេរិក អឺរុប ដែលបានបង្កើតការងារ ថ្មីជាច្រើនកន្លែង ។

២-ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវណែនាំសហគ្រាស គ្រឹះស្ថានសហការគ្នារៀបចំទិវា ០១ ឧសភា តាមរូបភាពដូចជា :

-ការជួបជុំសំណេះសំណាលតាមសហគ្រាស គ្រឹះស្ថាន ទទួលអំណរទិវា ០១ ឧសភា

-ការជួបជុំជប់លៀង កំសាន្តសប្បាយ ការដើរកំសាន្ត ដើម្បីបង្កបរិយាកាសសាមគ្គីភាព៖ ភាតរភាព នៅតាមសហគ្រាស គ្រឹះស្ថាន។

៣-ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថជាតិ អាជ្ញាធរខេត្ត-ក្រុង និងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវមានការណែនាំមន្ត្រី និងកងកំលាំងក្រោមសមត្ថកិច្ចរបស់ខ្លួនក្នុងការថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងបង្កលក្ខណៈងាយស្រួលដល់សហគ្រាស គ្រឹះស្ថាន ដែលមានទីតាំងក្នុងមូលដ្ឋានរបស់ខ្លួន ក្នុងឱកាសទិវាបុណ្យ ០១ ឧសភា ឆ្នាំ ២០០៣ នេះ ។

រាជរដ្ឋាភិបាលសូមអំពាវនាវដល់អង្គការវិជ្ជាជីវៈ សមាគម និងប្រជាពលរដ្ឋទាំងអស់ ចូលរួមអបអរទិវា ០១ ឧសភា ក្នុងក្តីសោមនស្សរីករាយ សាមគ្គីភាព ភាតរភាព ដើម្បីការអភិវឌ្ឍនៃប្រទេសជាតិយើង។

ទទួលបាននូវសារាចរណែនាំនេះ សូមឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគ្រប់ខេត្ត ក្រុង ត្រូវរៀបចំចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

" ដើម្បីជូនជ្រាប "

-គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន-ស្ថាប័ន និងខេត្ត-ក្រុង

" ដើម្បីសហការអនុវត្ត "

-ឯកសារ - កាលប្បវត្តិ